គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS
HROTP- IDA- KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - PDP - PJJ - VIGILANCE
#09, St 330, Sangkat Boeung Keng Kang 3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្តីប្រកាសព័ត៌មាន

## គោលដៅថ្មីសំរាប់ការចូលរួមរបស់ជនរងគ្រោះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅក្នុងឱកាស នៃ ការរៀបចំធ្វើកិច្ចប្រជុំពេញអង្គចៅក្រម កាលពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ ចៅក្រម នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) បានធ្វើវិសោធនកម្មទៅវិធានផ្ទៃក្នុង ជាពិសេសទៅលើបទប្បញ្ញត្តិទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអនុញ្ញាតឱ្យមានដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធិភាពនៅក្នុងសំណុំរឿង០០២ ដែលជាសំណុំរឿងដ៏សំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញនេះ។ បើយោងទៅតាមវិធានផ្ទៃក្នុងថ្មីដែលបានចេញផ្សាយជាសាធារណៈ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ កន្លងទៅនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្ស (CHRAC) ដែលជាសម្ព័ន្ធមានសមាជិកចំនួន ២៣ ធ្វើការលើវិស័យសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងជំនួយផ្នែកច្បាប់នៅកម្ពុជា សូមស្នើនូវយោបល់ទៅលើវិសោធនកម្មទាំងនេះ ដែលផ្តល់នូវគោលដៅថ្មីសំរាប់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ចាប់តាំងពីដំបូង សមាជិកមួយចំនួនរបស់គណៈកម្មាធិការប្រព្រឹត្តិកម្មបានជួយការងារអង្គជំនុំជម្រះវិសាមញ្ញតាមរយៈសកម្មភាពជាច្រើន ដោយផ្តោតជាពិសេសទៅលើ ការផ្សព្វផ្សាយទៅដល់សង្គមកម្ពុជា, ការគាំទ្រចំពោះការចូលរួមរបស់ជនរងគ្រោះ និងការសង្កេតឃ្លាំមើលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ជាលទ្ធផល សមាជិករបស់យើងបានជួយជនរងគ្រោះចំនួន ៤,៥០០នាក់ ឱ្យចូលរួមដាក់ពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះវិសាមញ្ញដែលកាលពីដំបូងឡើយបានបង្កើតឱ្យមានយន្តការនៃការចូលរួមរបស់ជនរងគ្រោះនៅក្រោមវិធានផ្ទៃក្នុងច្បាប់ដើម, មេធាវី, អង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយនានា សុទ្ធតែទទួលខុសត្រូវចំពោះជនរងគ្រោះទាំងនោះដែលបានចូលរួមក្នុងការផ្តល់សក្ខីកម្មទៅលើភាពរងគ្រោះរបស់គេ និង ដែលបានកំពុងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនីតិវិធីច្បាប់របស់តុលាការនេះ។

វិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មថ្មីនេះ ត្រូវបានធ្វើឡើងដើម្បី "ធ្វើឱ្យមានតុល្យភាពនូវសិទ្ធិរបស់គ្រប់ភាគីទាំងអស់និងធានាឱ្យអង្គជំនុំជម្រះវិសាមញ្ញមានលទ្ធភាពសំរេចឱ្យបាននូវអាណត្តិរបស់ខ្លួន" (នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលបានចេញផ្សាយកាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចលំអិតជាច្រើននៅតែមាន ហើយត្រូវតែបញ្ជាក់ឱ្យច្បាស់នៅក្នុងកិច្ចប្រជុំពេញអង្គលើកក្រោយ។

ដូចនេះ ដើម្បីឱ្យតុល្យភាពថ្មីនេះមានភាពត្រឹមត្រូវ និងគោរពទៅលើសិទ្ធិរបស់ជនរងគ្រោះ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមផ្តល់នូវអនុសាសន៍ដូចតទៅ:

ទី១ និងប្រហែលជាសំខាន់ជាងគេ គឺ គណៈកម្មាធិការប្រព្រឹត្តិកម្មសូមអបអរសាទរនូវការពង្រីកអាណត្តិរបស់អង្គភាពគាំពារជនរងគ្រោះ នៅក្រោមវិធាន ១២ *ស្ទួន (២)* ដោយរួមបញ្ចូលទាំង ការបង្កើត និងអនុវត្តនូវកម្មវិធី និងវិធានការនានាដែលមិនមែនតាមផ្លូវតុលាការ ដើម្បីបំរើផលប្រយោជន៍របស់ជនរងគ្រោះឱ្យកាន់តែទូលំទូលាយថែមទៀត។ ដើម្បីធ្វើដូចនេះបាន តុលាការទទួលស្គាល់នូវសេចក្តីត្រូវការបំពេញដំណើរការយុត្តិធម៌ព្រហ្មទណ្ឌជាមួយនឹងសមាសភាពយុត្តិធម៌បែបស្តារឡើងវិញសំរាប់ជនរងគ្រោះ។ បទប្បញ្ញត្តិពាក់ព័ន្ធទាំងនេះ មានលក្ខណៈធំទូលំទូលាយ និងដែលអនុញ្ញាតឱ្យអង្គភាពគាំពារជនរងគ្រោះអាចរៀបចំវិធានការនានា ដែលសមរម្យសំរាប់ជនរងគ្រោះដោយសាររបបខ្មែរក្រហម ដោយអនុវត្តន៍នូវយន្តការតាមបែបពិគ្រោះយោបល់ និងបែបចូលរួម។ កាលពីពេលកន្លងមក មានអង្គការសង្គមស៊ីវិលជាច្រើនដែលបានអនុវត្តន៍នូវគំនិតផ្តួចផ្តើម និងគំរោងជាច្រើនទាក់ទិននឹងជនរងគ្រោះ ដែលគួរតែអង្គភាពគាំពារជនរងគ្រោះអាចបង្កើតឱ្យមាន និងគិតគូរបន្ថែមទៀតអំពីគំនិតទាំងនេះបាន។ ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើដូចនេះបាន ក៏វាអាស្រ័យទៅលើការរៀបចំឱ្យមានបែបបទរដ្ឋបាល និងថវិកាបន្ថែមគ្រប់គ្រាន់ផងដែរ ផ្សេងពីថវិកាគោលរបស់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីធានាឱ្យមានការអនុវត្តន៍ប្រកដោយប្រសិទ្ធិភាព។ ដើម្បីកិច្ចការ នេះកើតឡើងទៅបាន អង្គភាពគាំទ្រជនរងគ្រោះ គួរតែទទួលបាននូវការគាំទ្រពីអង្គភាព ឬផ្នែកដទៃផ្សេងទៀតរបស់តុលាការឱ្យបានពេញលេញ ហើយការរៀបចំនានា គួរតែត្រូវចាប់ផ្តើមឱ្យបានឆាប់រហ័សផងដែរ។

ទី២- វិធានផ្ទៃក្នុងវិសោធនកម្មថ្មីនេះ បង្កើតឱ្យមានផ្នែកឯករាជ្យមួយទៀត គឺផ្នែកសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីតំណាងឱ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីដាក់បញ្ចូលគ្នាតែមួយនៅតំណាក់កាលអង្គសេចក្តី និងតំណាក់កាលក្រោយសវនាការ។ យោងទៅតាមវិធានផ្ទៃក្នុង ១២ស្ទួនពីរ (៣) សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីនេះ "ត្រូវស្វែងរកទស្សនៈយោបល់ទាំងឡាយពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងព្យាយាមសំរេចឱ្យបានការឯកភាពពីសំណាក់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅលើការតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ។" ទោះបីជាយ៉ាងក៏ដោយ វិធានផ្ទៃក្នុងថ្មីទាំងនេះ មិនបានផ្តល់នូវភាពលំអិតអំពីការអនុវត្តន៍ជាក់ស្តែង និងទុកឱ្យមាននីតិវិធីផ្ទៃក្នុងដែលត្រូវតែបង្កើតឱ្យមានទៅវិញនៅពេលអនាគតដ៏ខ្លីខាងមុខ។ ដូចនេះ យើងសូមទទូចដល់អង្គជំនុំជម្រះវិសាមញ្ញ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបច្ចុប្បន្ន ឱ្យចាប់ផ្តើមធ្វើសេចក្តីព្រាងនីតិវិធីផ្ទៃក្នុងទាំងនោះ ដើម្បីធានាឱ្យមានបទប្បញ្ញត្តិគ្រប់គ្រាន់ជាធរមាននៅមុនពេលសវនាការ ដោយធានាឱ្យមាននូវយន្តការសហការគ្នារវាងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង ដើម្បីជាផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងពហុទស្សនៈទាំងឡាយរបស់គេ ត្រូវបានតំណាងតាមផ្លូវច្បាប់នៅក្នុងតុលាការ។

ទី៣- គណៈកម្មាធិការប្រព្រឹត្តិកម្ម ក៏សូមស្វាគមន៍ចំពោះសេចក្តីសំរេចរបស់កិច្ចប្រជុំពេញអង្គ ដែលបានអនុម័តនូវវិធានការថវិកា និងរដ្ឋបាល ក្នុងការបង្កើតឱ្យមានការកើនឡើងនូវថវិកា ដែលបានទាមទារអស់ពេលដ៏យូរសំរាប់ការ

តំណាងផ្លូវច្បាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងពេលដែលមានដើមបណ្តឹងជាច្រើននៅក្នុងសំណុំរឿង ០០២ ដែលមិនទាន់មេធាវីហើយត្រូវការមេធាវីសំរាប់តំណាងគេនៅក្នុងប៉ុន្មានខែខាងមុខនេះ ហើយខណៈដែលមេធាវីមិនយកកំរៃនាពេលបច្ចុប្បន្នមានចំនួនតិច ដូចនេះ យើងក៏សូមទទូចឱ្យតុលាការ ផ្តល់ឱ្យទាន់ពេលវេលានូវធនធានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យមានភាពត្រឹមត្រូវ និងភាពសមរម្យក្នុងការតំណាងនូវផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីនៅគ្រប់តំណាក់កាល នៃដំណើរការនីតិវិធី។

នៅទីបញ្ចប់ យើងក៏រីករាយដោយបានមើលឃើញថា សំណើវិសោធនកម្មទាក់ទិននឹងវិធានស្តីពី សំណង នៅក្នុងក្របខណ្ឌរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានពន្យា ហើយនឹងត្រូវលើកយកទៅអនុម័តនៅឯកិច្ចប្រជុំពេញអង្គលើកក្រោយទៀត។ ការណ៍នេះ នឹងផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ចៅក្រម ដើម្បីធ្វើការគិតគូរគោលនយោបាយស្តីពី សំណង និងការអនុវត្តសំណងនៅក្នុងរបៀបមួយបែបវៃឆ្លាត និងពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត។ គណៈកម្មាធិការប្រព្រឹត្តិកម្ម ធ្លាប់បានលើកឡើងនូវការព្រួយបារម្ភជាខ្លាំងរបស់ខ្លួនទៅលើវិសោធនកម្មវិធានទាំងនេះម្តងរួចហើយ ដូចនេះ នៅពេលនេះ ខ្លួនក៏បានត្រៀមខ្លួនរួចជាស្រេចដែរ ដើម្បីបន្តចូលរួមនៅក្នុងកិច្ចពិភាក្សាជាមួយនឹងតុលាការសំរាប់ស្វែងរកដំណោះស្រាយប្រកបដោយអត្ថន័យ និងមានលក្ខណៈទន់ភ្លន់ ចំពោះអាណត្តិរបស់តុលាការនេះ ទាក់ទិននឹងបញ្ហាសំណងជាសមូហភាព និងសំណងផ្លូវចិត្ត។

ទោះបីជាយ៉ាងណាក៏ដោយ ក្រៅពីការធ្វើការកែសំរួលវិធានផ្ទៃក្នុងទាំងនេះ ក្របខណ្ឌដែលអាចឱ្យមានប្រសិទ្ធភាព និងមានន័យសំរាប់ការចូលរួមរបស់ជនរងគ្រោះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ត្រូវការពិតប្រាកដនូវការប្តេជ្ញាចិត្តពីគ្រប់អ្នកធ្វើសេចក្តីសំរេចចិត្តទាំងអស់ ហើយក៏ត្រូវការឱ្យមានការរៀបចំបែងចែកនូវធនធានគ្រប់គ្រាន់ទៅដល់អង្គភាពគាំពារជនរងគ្រោះ, អង្គការសង្គមស៊ីវិល, សមាគមជនរងគ្រោះ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជួយឱ្យការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការកាត់សេចក្តីនេះជាបទពិសោធន៍ដ៏មានអត្ថប្រយោជន៍។ អ្វីផ្សេងក្រៅពីនេះ *ការចូលរួម* របស់ជនរងគ្រោះ ហាក់ដូចគ្រាន់តែជាការសន្យាខ្យល់ប៉ុណ្ណោះ។

*ភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០*


***សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងជាមួយ:***

| | | |
|---|---|---|
| លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| លោក **ធន សារាយ** | ប្រធានសមាគមអាដហុក | ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩ |
| លោក **សុក សំអឿន** | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោក **វុន សារាយ** | នាយកប្រតិបត្តិអង្គការ LAC | ទូរស័ព្ទលេខ: ០១២ ៨៣៨ ៣៤១ |